ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៦៤៤ ឧរ៉ថ.ឧ៨.ប្រក.

# ប្រកាស

## ស្តីពី

## ការបង្កើតអង្គភាពផលិតភាព ចំណុះនាយកដ្ឋានកិច្ចការឧស្សាហកម្ម

**************

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញប្រកាស លេខ១៩៥ បល.ប្រក ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានកិច្ចការឧស្សាហកម្ម
- បានឃើញលិខិតលេខ ៣២០សជណ.ឧស ចុះថ្ងៃទី០៥ ខែមិនា ឆ្នាំ២០០៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់ អគ្គនាយកដ្ឋានឧស្សាហកម្ម និង
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង

## <u>សំរេច</u>

<u>ប្រការ១</u>: ត្រូវបានបង្កើតអង្គភាពផលិតភាព បន្ថែមទៅក្នុងរចនាសម្ព័ន្ធរបស់នាយកដ្ឋានកិច្ចការឧស្សាហកម្ម

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ :(៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣. ៤២៨២៦៣
45 Preah Norodom Boulevard , Khan Daun Penh, Phnom Penh , Phone : 855. 23 . 211141 Fax : 855 23 428263

**តួនាទី:**

អង្គភាពផលិតភាពជាសេនាធិការអោយថ្នាក់ដឹកនាំនាយកដ្ឋានលើការងារគ្រប់គ្រង និង ជំរុញការលើកកំពស់ផលិតភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ភារកិច្ច:**

- បំពេញភារៈកិច្ចនិងអនុវត្តកាតព្វកិច្ចក្នុងនាមជាសមាជិកអង្គការផលិតភាពអាស៊ី
- គ្រប់គ្រង សម្របសំរួល និងជំរុញការលើកកំពស់កំណើនផលិតភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលជាមួយវិស័យឯកជននិងក្រសួងឬស្ថាប័នពាក់ព័ន្ធដើម្បីលើកកំពស់ផលិតភាពការងារនិងសេដ្ឋកិច្ច
- ទំនាក់ទំនងទ្វេភាគី ឬ ពហុភាគីជាមួយអង្គការផលិតភាពជាតិនៃបណ្តាប្រទេសនានា
- រៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា ក្នុងទិសដៅអភិវឌ្ឍវិស័យផលិតភាពសំរាប់សេដ្ឋកិច្ច-សង្គម
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រង និងផ្សព្វផ្សាយឯកសារពិតមានផលិតភាព
- សហការ ឬ ផ្តល់សេវាកម្ម ពិគ្រោះយោបល់ និងបណ្តុះបណ្តាលលើផ្នែកផលិតភាព

**ប្រការ២** :អង្គភាពផលិតភាព ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ប្រការ៣** : អង្គភាពផលិតភាពមានរចនាសម្ព័ន្ធដូចតទៅៈ

- ផ្នែករដ្ឋបាល : ទទួលបន្ទុកការងាររដ្ឋបាល បុគ្គលិក និងលិខិតបទដ្ឋាននានារបស់អង្គភាព។
- ផ្នែកលើកកំពស់និងជំរុញផលិតភាព: ទទួលបន្ទុកលើកកំពស់និងជំរុញចលនាផលិតភាព
- ផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍: ទទួលការងារស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រង និងផ្សព្វផ្សាយឯកសារពិតមានលើវិស័យផលិតភាព
- ផ្នែកពិគ្រោះយោបល់និងបណ្តុះបណ្តាលៈ ទទួលផ្តល់សេវាកម្មពិគ្រោះយោបល់ និងបណ្តុះបណ្តាល បច្ចេកទេសបង្កើនផលិតភាព។

**ប្រការ៤**: បទប្បញ្ញត្តិ និង សេចក្តីសំរេចទាំងឡាយណាដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវ

ចាត់ទុកជានិរាករណ៍ ។

<u>ប្រការ៥</u>: អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម មានភារៈកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀង១ខ្លួនតាមប្រកាសនេះ ។

<u>ប្រការ៦</u>: ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានី.ភ្នំពេញថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០៤

ស៊ុយ_សែម

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់នាយកដ្ឋាន
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្ត-ក្រុង

  " ដើម្បីជ្រាបជាពតិមាន"
- ដូចប្រការ៥" ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

តារាងឧបសម្ព័ន្ធទី១ នៃប្រកាសលេខ : ៧៤៤ ឧស្សាហកម្ម.ប្រក
ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤

**អង្គភាពលេខ អង្គភាពផលិតភាព**

- ប្រធានអង្គភាព
  - អនុប្រធានអង្គភាព
    - ផ្នែករដ្ឋបាល
    - ផ្នែកជំរុញនិងលើកកំពស់ផលិតភាព
    - ផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍
    - ផ្នែកពិគ្រោះយោបល់និងបណ្តុះបណ្តាល

បានឃើញ
ភ្នំពេញ,ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០៤
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
ស៊ុយ_សែម

បានឃើញ
ភ្នំពេញ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៤
អគ្គនាយកឧស្សាហកម្ម
ឌួង _ សៅ

ភ្នំពេញ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ០៤
ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម
កែវ_សុវត្ថិ